ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២០៦
ចុះថ្ងៃទី២៤-០៣-២០១០
**សាលដីកា**
លេខ: ១៨ "ឍ"
ចុះថ្ងៃទី២១-១២-២០១០

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០ដោយមានសមាសភាពដូចខាងក្រោម:

**សមាសភាពក្រុមប្រឹក្សា**

-លោកស្រី [redacted] ប្រធាន
-លោក [redacted] ចៅក្រមប្រឹក្សា
-លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី គួច ប៊ុនី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២០៦ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១០ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរព្រះសង្ឃ ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន។

-ត្រូវចោទពីបទ៖ ប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិកំពង់គរ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៩។

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ [redacted]។

**៦រឿងហេតុមានដូចតទៅ:**

កាលពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទីយប់ ស្ថិតនៅវត្តពិជ័យសាគរ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា ដោយធ្លាប់មានទំនាស់ពាក្យសំដីជាមួយជនរងគ្រោះឈ្មោះ [redacted] គិត បានប្រើល្បិចបោកចានទៅមុខបន្ទប់ដេករបស់ជនរងគ្រោះ ដើម្បីឲ្យជនរង

គ្រោះ ដើម្បីឲ្យជនរងគ្រោះបើកចេញមកក្រៅ។ ដោយលីសូរបែក ជនរងគ្រោះក៏បានបើកទ្វារចេញមកព្រ ស្រាប់តែជនជាប់ចោទមានពាក់ហង្សស័ក្ក ប្រដាប់ដំបងវាយទៅលើជនរងគ្រោះចំនួន ០២ដង បណ្ដាល មានរបួសត្រង់ផ្នែកក្បាលយ៉ាងធ្ងន់ធ្ងរ រួចដួលសន្លប់នៅហ្នឹងកន្លែង។ លុះដល់ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០០ ជនជាប់ចោទត្រូវបានសមត្ថកិច្ចចាប់ខ្លួនបាន។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៨ ក វ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលា ដំបូងខេត្តកណ្ដាល ដែលបានសម្រេចសេចក្ដីដូចខាងក្រោម៖

១.កែប្រែបទចោទពីបទ ប៉ុនប៉ងមនុស្សឃាតគិតជាមុន តាមមាត្រា៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋមកបទ ប៉ុនប៉ងមនុស្សឃាតដោយចេតនា តាមមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស នៃបទ ឧក្រិដ្ឋ។

២.ផ្ដន្ទាទោសឈ្មោះ [redacted] វ៉ាន់ដា ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១ ឆ្នាំ (ដប់ឆ្នាំ) គិតពីថ្ងៃឃុំខ្លួនទី ០៩ ខែមីនា ឆ្នាំ២០០៩។

ពីបទ៖ ប៉ុនប៉ងមនុស្សឃាតគិតជាមុន ប្រព្រឹត្តនៅភូមិកំពង់គរ ឃុំពោធិបាន ស្រុកកោះធំ ខេ កណ្ដាល កាលពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៩។

បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ'

៣.បង្គាប់ឲ្យឈ្មោះ [redacted] វ៉ាន់ដា សងការខូចខាត និងសងជម្ងឺចិត្តជាប្រាក់ចំនួន ១.០០០.០០០រៀល (មួយលានរៀល) ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិតពីថ្ងៃចេញសាលក្រមចូលជាស្ថាពរ កា ទាមទារលើកពីនេះ ត្រូវលើកចោល។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខដើម បណ្ដឹងរដ្ឋប្បវេណី ទុកពេលប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**<u>នាពេលសវនាការ</u>**

**<u>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានអានរបាយការណ៍រឿង</u>**

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា ( វត្តមាន )

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិត ( អវត្តមាន )

-ក្រឡាបញ្ជីបានអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា បានឆ្លើយថា ថ្ងៃកើតហេតុ ខ្លួនមិនបានទៅទេ ខ្លួនទៅផ្ទះញោម ឈ្មោះ ជាត អង្គុយលេងមួយសន្ទុះម៉ោងប្រហែល ៧ មានភ្លើងឆេះខាងក្រោយវត្ត ខ្លួនក៏ជួយពន្លត់ភ្លើង ហើយដើរមកផ្ទះឈ្មោះ ជាត វិញមើលទូរទស្សន៍ និងបាននិយាយជាមួយប្រពន្ធ ម៉ាំង ជាត ប្រហែល ១៥ នាទី។ រឿងរ៉ាវនៅវត្តខ្លួនមិនដឹងទេ និងមិនបានវាយយាយ [redacted] គិត ទេ ខ្លួនជាភិក្ខុធម្មតា ខ្លួនធ្លាប់បួសបាន សឹកម្ដងហើយ ខ្លួនសំរាកឆ្ងាយពីយាយ [redacted] គិត ប្រហែលពី ៥០ ទៅ ១០០ម ពីគ្នា។ យាយ ម៉ី គិត គាត់មិន ពេញចិត្តចៅអធិការវត្តទេ គាត់ចូលចិត្តលោក រិន ជាងខ្លួនធ្លាប់មានទំនាស់ពាក្យសំដីជាមួយយាយ [redacted] គិត

ពីរឿង យកអង្ករទៅបបរ ដោយមិនបានប្រាប់គាត់ឲ្យដឹង។ គេចាប់ខ្លួននៅម៉ោង ៧យប់ ប៉ូលីសជាអ្នកសួចម្លើយ ហើយយកទៅឃុំនៅស្រុក។ ខ្លួនសុំឲ្យតុលាការជួយលើកលែងទោសឲ្យខ្ញុំផង។

## តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

ក្រោយពីបានពិនិត្យចម្លើយជនរងគ្រោះ សាក្សី និងបានពិនិត្យទៅលើអង្គហេតុឃើញថា ពុំមារកោសល្យវិច័យពេទ្យ បញ្ជាក់ពីរបួសស្នាមរបស់ជនរងគ្រោះ គ្មានឯកសារបញ្ជាក់ពីរបួសស្នាមឲ្យឃើញនៃចេតនា នៃបទប៉ុនប៉ងមនុស្សឃាតដោយចេតនានោះទេ គប្បីប្ដូរមកបទចោទទៅជាបទបង្ករបួសដោយចេតនាវិញ។ គួរសភាព្រហ្មទណ្ឌពិចារណាទៅតាមច្បាប់។

## មេធាវីធ្វើសេចក្ដីសន្និដ្ឋាន

តំណាងអយ្យការបានលើកឡើងពិតជាត្រឹមត្រូវហើយ។ កូនក្ដីខ្លួនបានថា វ៉ៃ ២ដំបង ក៏ដួលសន្លប់តែគ្មានសាក្សីឃើញផ្ទាល់ភ្នែកទេ។ សំណូមពរសុំឲ្យកូនក្ដីខ្លួន រួចផុតពីបទចោទ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យ ឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន។

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

## សំអាងហេតុ យល់ឃើញថា:

១-បណ្ដឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា បានឆ្លើយប្រកែកដោះសារថា មិនបានគុំគួន និងវាយទៅលើយាយ [redacted] គិត បណ្ដាលឲ្យរបួសសន្លប់ទេ គ្រាន់តែធ្លាប់មានទំនាស់ជាមួយយាយ [redacted] គិត បន្តិចបន្តួចប៉ុណ្ណោះ។ ចម្លើយនេះ គឺជាចម្លើយដោះសារតែប៉ុណ្ណោះ បើពិនិត្យលើចម្លើយរបស់ឈ្មោះ ម៉ាំង ជាត និងឈ្មោះ ជាត សុភាព ដែលជាសាក្សីដោះបន្ទុកក៏បានឆ្លើយខុសគ្នាខ្លះៗនៅសមត្ថកិច្ច ចៅក្រមស៊ើបសួរ ក៏ដូចពេលសវនាការនិយាយអំពីការកំណត់ម៉ោងរបស់ជនជាប់ចោទបានទៅដល់ផ្ទះគាត់ និងកោសខ្យល់ហើយមកមើលយាយ គិត សន្លប់គឺមានការប្រែប្រួលក្នុងចន្លោះម៉ោងដែលជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា។

១៤៦

បានឃើញសកម្មភាពរួចហើយ បើពិនិត្យលើចម្លើយជនរងគ្រោះ ចម្លើយសាក្សីបំភ្លឺឈ្មោះ ម៉ាំង ពិសិដ្ឋ និងម៉ោងនៃការចេញដំណើរ និងចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]វ៉ាន់ដា ពិតជាប៉ុនប៉ងសម្លាប់ជន រងគ្រោះដោយសារគំនុំផ្ទាល់ខ្លួនដែរ។

-ព្រោះនៅក្នុងអង្គហេតុនេះ គ្មានសាក្សី ឬឯកសារណាគួរឲ្យមន្ទិលសង្ស័យទៅលើសកម្មភាពរបស់ជនផ្សេង ក្រៅពីជនជាប់ចោទឡើយ។ គឺមានតែស្នាមមេដៃដែលដាក់ថាៈ ជាប្រជាពលរដ្ឋ ១១៧គ្រួសារ ដែលស្ថិតនៅក្នុងភូមិលេខ ៦, ៧, ៨ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល សូមធ្វើការគាំទ្រយុវជនឈ្មោះ នី វ៉ាន់ដា ជាពលរដ្ឋបែបណាឡើយ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ០៨ ក វ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចសេចក្តីត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គ្រាន់តែពុំបានលើកឡើង អំពីភស្តុតាង និងវត្ថុតាងដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងនៅអយ្យការ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០០៩ មកសម្រេចបំផ្លាញ គប្បីសាលាឧទ្ធរណ៍សម្រេចបន្ថែមត្រង់ចំណុចនេះ។

**ហេតុដូច្នេះ វិនិច្ឆ័យសេចក្តីៈ**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted]វ៉ាន់ដា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៨ ក វ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល។

៣-រឹបអូសវត្ថុតាងដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងនៅអយ្យការ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០០៩ ដើម្បីបំផ្លាញចោល។

៤-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]វ៉ាន់ដា តាមច្បាប់។

សាលដីកានេះ ជំនុំជម្រះជាសារធារណៈនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការណ៍អនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted], [redacted] | ហត្ថលេខាៈ [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

១៤៧

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី..៨..ខែ..១...ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]